**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

ថ្ងៃ សុក្រ ៨រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

លេខ ២៨១/២៣ ក.ស.ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២៣

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការបែងចែកភាគលាភ ប្រចាំឆ្នាំ២០២២ របស់កំពង់ផែស្វយ័តភ្នំពេញ

**កំពង់ផែស្វយ័តភ្នំពេញ** (**ក.ស.ភ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" របស់ ក.ស.ភ. ទាំងអស់មេត្តាជ្រាបថា យោងតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិកលើកទី៨ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ក.ស.ភ. សម្រេចធ្វើការបែងចែកភាគលាភប្រចាំឆ្នាំ២០២២ ដូចខាងក្រោម៖

១. ប្រភេទភាគលាភដែលត្រូវបែងចែក (Type of Dividend) : **សាច់ប្រាក់**

២. រយៈពេលភាគលាភ (Dividend Period) : **ប្រចាំឆ្នាំ ២០២២**

៣. ចំនួនភាគហ៊ុនដែលបានចុះបញ្ជីសរុប : **២០.៦៨៤.៣៦៥ ភាគហ៊ុន**
- ភាគហ៊ុនិកប្រភេទ "ក" : **៤.១៣៦.៨៧៣ ភាគហ៊ុន**
- ភាគហ៊ុនិកប្រភេទ "ខ" : **១៦.៥៤៧.៤៩២ ភាគហ៊ុន**

៤. អនុបាតនៃការបែងចែកភាគលាភសរុប (Total Dividend Payout Ratio) : **៧,៩១ %**
- អនុបាតនៃការបែងចែកសម្រាប់ភាគហ៊ុនិកប្រភេទ "ក" : **២,៤៤ %**
- អនុបាតនៃការបែងចែកសម្រាប់ភាគហ៊ុនិកប្រភេទ "ខ" : **៥,៤៧ %**

៥. ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend to be paid) : **៤.៦២៩.៧០៣.៣០៩ រៀល**
- ភាគលាភសរុបសម្រាប់ភាគហ៊ុនិកប្រភេទ "ក" : **១.៤២៩.៧០៣.៣០៩ រៀល**
- ភាគលាភសរុបសម្រាប់ភាគហ៊ុនិកប្រភេទ "ខ" : **៣.២០០.០០០.០០០ រៀល**

៦. ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសរុប (Total Dividend per Share) : **២២៣,៨៣ រៀល**
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនិកប្រភេទ "ក" : **៣៤៥,៦០ រៀល**
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនិកប្រភេទ "ខ" : **១៩៣,៣៨ រៀល**

៧. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ (Record Date): **ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣**

៨. កាលបរិច្ឆេទចាប់ផ្ដើមទូទាត់ភាគលាភ (Payment Date) : **ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣**



ទីស្នាក់ការកណ្ដាល: អគារលេខ ៦៤៩ តីវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨២៧ ៨០២ Email: ppapmpwt@online.com.kh

**<u>សូមបញ្ជាក់៖</u>**

- *ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន* ***នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣*** *នៅតែមានសិទ្ធិទទួលបានភាគលាភដដែល*
- *ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិ* ***នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣*** *នឹងមិនមានសិទ្ធិទទួលបានភាគលាភទេ*
- *ការទូទាត់ភាគលាភជូនភាគហ៊ុនិកចាប់ផ្តើមពី* ***ថ្ងៃទី០៥ ខែមិថុនា ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣*** *នៅរៀងរាល់ថ្ងៃធ្វើការ។*

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទំនាក់ទំនងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ ក.ស.ភ. ដូចខាងក្រោម៖

- ឈ្មោះ៖ **ធនាគារ អេស៊ីលីដា ភីអិលស៊ី**
- អាសយដ្ឋាន៖ ជាន់ទី៥ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

**១. លោក ហួត សុភី** : ប្រធានផ្នែកប្រតិបត្តិការ RTP
- សទូរស័ព្ទ : (៨៥៥) ១៥ ៩០០ ៥៣៨
- អ៊ីម៉ែល : huot.sophy@acledabank.com.kh

**២. លោក កែន រិទ្ធពុទ្ធា** : អ្នកឯកទេសបឋមប្រតិបត្តិការ RTP
- ទូរស័ព្ទ : (៨៥៥) ១៥ ៨០០ ៦៦៣
- អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

**៣. លោកស្រី សំរិទ្ធ វណ្ណិបុប្ផារដ្ឋ** : បុគ្គលិកជាន់ខ្ពស់ផ្នែកប្រតិបត្តិការ RTP
- ទូរស័ព្ទ : (៨៥៥) ៦១ ២៨៧ ៧៦៦
- អ៊ីម៉ែល: op.rtp@acledabank.com.kh

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

**ហ៊ឺ~ធ្មាធិ**

**<u>ចម្លងជូន៖</u>**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-និយ័តករមូលបត្រកម្ពុជា (ន.ម.ក.)
-ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)
-សមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.
-សវនករផ្ទៃក្នុងរបស់ ក.ស.ភ.
-សវនករឯករាជ្យរបស់ ក.ស.ភ. - ក្រុមហ៊ុន BDO
*<u>"ដើម្បីគោរពជូនជ្រាប"</u>*
-ធនាគារ អេស៊ីលីដា ភីអិលស៊ី
(ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់)
*<u>"ដើម្បីសហការផ្សព្វផ្សាយ"</u>*
-ឯកសារ-កាលប្បវត្តិ